**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**បេឡាជាតិរបបសន្តិសុខសង្គម**

លេខ : ១៤/០៩ ប.ស.ស

# <u>សេចក្តីជូនដំណឹង</u>

បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) មានកិត្តិយសសូមជម្រាបជូនដល់អស់លោក លោកស្រីនាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ដែលបានចុះបញ្ជិកាក្នុង ប.ស.ស រួចហើយសូមមេត្តាជ្រាបថា កន្លងមកមានបណ្តាសហគ្រាស គ្រឹះស្ថានមួយចំនួនពុំទាន់បានចុះបញ្ជិកាសាខាសហគ្រាស គ្រឹះស្ថានរបស់ខ្លួននៅតាមបណ្តាខេត្ត ក្រុងនានា ឬនៅតាមបណ្តាទីតាំងផ្សេងៗដទៃទៀតឡើយ ចំណែកឯសហគ្រាស គ្រឹះស្ថានខ្លះទៀត មិនបានរាយការណ៍ និងមិនបានបង់ភាគទានទៅតាមចំនួនកម្មករនិយោជិតជាក់ស្តែងឡើយ ករណីនេះបេឡាជាតិរបបសន្តិសុខសង្គមនឹងអនុវត្តន៍តាមគោលការណ៍ច្បាប់ និងបទដ្ឋានគតិយុត្តជាធរមានយ៉ាងតឹងរឹង និងម៉ឺងម៉ាត់បំផុត ៖

១- ករណីមិនចុះបញ្ជិកាសាខាសហគ្រាស គ្រឹះស្ថាននៅតាមបណ្តាខេត្ត ក្រុងនានា ឬនៅតាមបណ្តាទីតាំងផ្សេងៗដទៃទៀត ត្រូវពិន័យជាប្រាក់ក្នុងកំរិតអប្បបរមាស្មើនឹង *១០ថ្ងៃ x ៨០០០៛* បើនៅតែមិនរាងចាល ការពិន័យនេះត្រូវតម្លើងស្មើនឹង *៣០ថ្ងៃ x ៨០០០៛*។

២- ករណីមិនរាយការណ៍កម្មករនិយោជិត ពិន័យជាប្រាក់ក្នុងកំរិតអប្បបរមាស្មើនឹង *ចំនួនកម្មករនិយោជិត ដែលមិនបានរាយការណ៍ x ១០ថ្ងៃ x ៨០០០៛ បូកបន្ថែមទាំងប្រាក់ភាគទានគិតចាប់ពីខែដែលកម្មករនិយោជិតម្នាក់ៗចូលធ្វើការរហូតដល់ខែចុងក្រោយ ព្រមទាំងការប្រាក់នៃប្រាក់ភាគទានទាំងអស់ផង ។ បើនៅតែមិនរាងចាលការពិន័យនេះត្រូវតម្លើងស្មើនឹង ចំនួនកម្មករនិយោជិតដែលមិនបានរាយការណ៍ x ៣០ថ្ងៃ x ៨០០០៛ បូកបន្ថែមប្រាក់ភាគទាន និងការប្រាក់ដូចបានបញ្ជាក់ខាងលើ។*

ទទួលបានសេចក្តី ជូនដំណឹងនេះ សូមអស់លោក លោកស្រីនាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ចូលរួមអនុវត្តន៍តាមខ្លឹមសារខាងលើដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត ។

ឈ្មោះសហគ្រាស គ្រឹះស្ថានៈ

..............................................................

លេខអត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | | |

ថ្ងៃទី..........ខែ.........ឆ្នាំ២០......

ហត្ថលេខាអ្នកទទួលលិខិត

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែ ធ្នូ ឆ្នាំ២០០៩

នាយក

អ៊ុក សមវិទ្យា

ឈ្មោះ..............................................

តួនាទី..............................................

ទូរស័ព្ទ..............................................

អាសយដ្ឋានអគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី ទូរស័ព្ទៈ ០២៣-៨៨ ២៤ ៣៤ . ០២៣ ៩៩ ៨៤ ១៧ ទូរសារ : ០២៣ ៨៨ ២៦ ២៣. ប្រអប់សំបុត្រ P.O.Box 70
Website : www.nssf.gov.kh